**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)
លេខៈ ៥៣៤/២២ គ.វ.ក-១៩

ថ្ងៃ ចន្ទ ៩រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២២

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការក្រើនរំលឹកការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ដល់ក្រុមអាយុចាប់ពី ៥ឆ្នាំឡើង

យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២២ ក្នុងឱកាសពិធីប្រគល់-ទទួលអំណោយវ៉ាក់សាំងអាស្ត្រាហ្សេនីកា ដែលជាជំនួយដ៏ថ្លៃថ្លារបស់រដ្ឋាភិបាល និងប្រជាជនអ៊ីតាលី គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (**គ.វ.ក-១៩**) សូមគោរពជម្រាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា បច្ចុប្បន្ននេះ **គ.វ.ក-១៩** កំពុងបន្តការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ ជូនដល់ក្រុមអាយុចាប់ពី៥ឆ្នាំឡើង នៅតាមមន្ទីរពេទ្យជាតិនានា មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងទីតាំងចាក់ វ៉ាក់សាំងកូវីដ-១៩ ដែលបានរៀបចំចាក់ជូនដោយមន្ទីរពេទ្យជាតិនានា និងរដ្ឋបាលរាជធានី-ខេត្តទាំង២៥។ ដោយពិនិត្យឃើញថាក្រុមអាយុចាប់ពី៥ឆ្នាំឡើងបានមកទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ នៅមានកម្រិតនៅឡើយ **គ.វ.ក-១៩** សូមធ្វើការក្រើនរំលឹកដល់អ្នកដែលនៅក្នុងក្រុមអាយុចាប់ពី៥ឆ្នាំឡើង ហើយដល់វេនចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងដូសទី៣ ឬដូសជំរុញ នៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងទីតាំង ចាក់វ៉ាក់សាំងកូវីដ-១៩ រៀងរាល់ថ្ងៃ (រួមទាំងថ្ងៃឈប់សំរាក ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ដោយត្រូវយកភ្ជាប់ទៅជាមួយនូវប័ណ្ណចាក់ វ៉ាក់សាំងកូវីដ-១៩។

ទន្ទឹមគ្នានេះដែរ គ.វ.ក-១៩ សូមជម្រាបជូនសាធារណជនជ្រាបថា ចំពោះកុមារ យុវវ័យ និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី៥ឆ្នាំឡើង អាចទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ បន្ទាប់ពីបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ឬបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ រយៈពេលចាប់ពី៣ខែឡើង ដើម្បីពង្រឹង និងបង្កើនប្រព័ន្ធភាពស៊ាំបុគ្គល និងសហគមន៍ឱ្យបានទាន់ពេលវេលា ដែលអាចឱ្យយើងរំដោះខ្លួនចេញផុតពីការយាយីធ្ងន់ធ្ងរ នៃវីរុសកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុងដែលកំពុងបន្តចរាចរនៅក្នុងសហគមន៍នៅឡើយ ក៏ដូចជាវីរុសបំប្លែងខ្លួនថ្មីផ្សេងៗទៀត ដែលកំពុងចរាចរយ៉ាងសកម្មនៅក្នុងតំបន់ និងនៅក្នុងសកលលោកនាពេលបច្ចុប្បន្ននេះ។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ / លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០១២ ៩១៦ ០៩៩ | ០១០ ២៣៣ ៥៨៨ |



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យាៈ

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យៈ

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.ច.ក-១៩)**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**